**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ១៨-០១៩-០២១ ប្រកាសព័ត៌មាន

ថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Retail Pay

នៅថ្ងៃពុធ ៣រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើប្រាសាក់ ធនាគារអេស៊ីលីដា ធនាគារប្រៃសណីយ៍កម្ពុជា ធនាគារវឌ្ឍនៈ ធនាគារកាណាឌីយ៉ា ធនាគារគូកមីន ធនាគារភ្នំពេញពាណិជ្ជ បានដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Retail Pay ដែលជាបណ្តុំនៃប្រព័ន្ធទូទាត់រាយចំនួន ៣ និងប្រព័ន្ធជាត់ទាត់ចំនួន ១ ដែលរួមមាន ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (Real-Time Fund Transfer "RFT") ប្រព័ន្ធទូទាត់ចល័ត (Mobile Payment System "MPS") ប្រព័ន្ធទូទាត់តាមរយៈ QR កូដ (QR-Code Payment System "QPS") និងប្រព័ន្ធជាត់ទាត់អេឡិចត្រូនិក (Electronic Clearing System "ECS")។

គោលបំណងនៃការដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Retail Pay គឺ ដើម្បីធ្វើទំនើបកម្មលើប្រព័ន្ធទូទាត់រាយប្រកបដោយនវានុវត្តភាព ជំរុញការធ្វើប្រតិបត្តិការអន្តរធនាគារ បង្កើនប្រសិទ្ធភាពប្រតិបត្តិការ លើកកម្ពស់សុវត្ថិភាពនៃការផ្ទេរមូលនិធិតាមរយៈការផ្តល់មធ្យោបាយទូទាត់អេឡិចត្រូនិក ដែលមានភាពរហ័ស សុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់អតិថិជន។ ម្យ៉ាងវិញទៀត ប្រព័ន្ធទូទាត់រាយខាងលើនឹងរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងសម្រួលដល់លំហូរមូលនិធិនៅលើទីផ្សារ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ព្រះរាជាណាចក្រកម្ពុជា
ធនាគារជាតិនៃកម្ពុជា

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ៖ (៨៥៥) ១២ ៣៩៣ ៦០០/ (៨៥៥) ៩៨ ៥៧៩ ៨៨៧
Email៖ nbccommunication@nbc.org.kh / psd@nbc.org.kh